ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ: ៣១៤៧ មស.ឱក

សូមគោរពជូន

**សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន និង ឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ:** ស្តីពីការស្នើសុំឬលុបប្រាក់វិភាជន៍គ្រួសារមន្ត្រីរាជការស៊ីវិល ។

**យោង:**
- ព្រះរាជក្រឹត្យលេខ នស/រកត/០១១៤/០១៧ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា២៥នៃព្រះរាជក្រឹត្យលេខ នស/កត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- អនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៨ ស្តីពីការតំឡើងប្រាក់ឧបត្ថម្ភប្រចាំខែជូនប្រពន្ធ-ប្តីនិងកូនរបស់មន្ត្រីរាជការស៊ីវិល កងយោធពលខេមរៈភូមិន្ទ កងកម្លាំងនគរបាលជាតិ និវត្តជន មន្ត្រីបាត់បង់សមត្ថភាពពលកម្ម និងយុទ្ធជនពិការ ។

ខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូនសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និង ឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត មេត្តាជ្រាបថា ដើម្បីសម្រួលដល់ការស្នើសុំឬលុបប្រាក់វិភាជន៍គ្រួសារមន្ត្រីរាជការស៊ីវិល និង ចូលរួមពង្រឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្តដូចមានយោងខាងលើ និង លិខិតបទដ្ឋានគតិយុត្តជាធរមានឱ្យមានប្រសិទ្ធភាព ក្រសួងមុខងារសាធារណៈ សូមគោរពស្នើសុំសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និង ឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ចូលរួមសហការ អនុវត្តខ្លឹមសារដូចបានកំណត់ខាងក្រោម៖

- ជារៀងរាល់ដើមខែ មន្ត្រីរាជការស៊ីវិលដែលមានបំណងស្នើសុំឬលុបប្រាក់វិភាជន៍គ្រួសារ ត្រូវយកឯកសារពាក់ព័ន្ធពិតប្រាកដដូចជា សំបុត្រកំណើតឬសេចក្តីចម្លងសំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ឬសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ សំបុត្រមរណភាពឬសេចក្តីចម្លងសំបុត្រមរណភាព សាលក្រមលែងលះស្ពាពឬសេចក្តីចម្លងសាលក្រមលែងលះស្ពាព ឬ ឯកសារពាក់ព័ន្ធជាធរមានផ្សេងទៀតចំនួនមួយច្បាប់ ជូនមន្ត្រីទទួលបន្ទុកការងារបុគ្គលិកឱ្យបានទាន់ពេលវេលា
- មន្ត្រីទទួលបន្ទុកការងារបុគ្គលិក បន្ទាប់ពីទទួលបានឯកសារពាក់ព័ន្ធពិតប្រាកដពីមន្ត្រីរាជការស៊ីវិល ត្រូវពិនិត្យនិងរៀបចំឱ្យទាន់ពេលវេលានូវបញ្ជីរាយនាមកូន និង/ឬ សហព័ន្ធរបស់មន្ត្រីរាជការស៊ីវិលដែលស្នើសុំឬលុបប្រាក់វិភាជន៍គ្រួសារចំនួនពីរច្បាប់ ដោយមានចុះហត្ថលេខា



អាសយដ្ឋាន: (កែងផ្លូវម៉ៅសេទុងនិងផ្លូវលេខ២០០៤) ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ទូរស័ព្ទ.ទូរសារ(៨៥៥) ២៣ ៨៦៦ ៥០១

ទទួលខុសត្រូវពីប្រធាននាយកដ្ឋានបុគ្គលិកនិងរដ្ឋមន្ត្រីប្រធានស្ថាប័ន សម្រាប់ថ្នាក់ជាតិនិងពីនាយកទីចាត់ការធនធានមនុស្សនិងអភិបាលរាជធានី ខេត្ត ឬ ប្រធានអង្គភាពគ្រប់គ្រងបុគ្គលិកនិងប្រធានមន្ទីរ/អង្គភាពជំនាញរាជធានី ខេត្ត សម្រាប់ថ្នាក់ក្រោមជាតិ

- បញ្ជីរាយនាមកូន និង/ឬ សហព័ន្ធរបស់មន្ត្រីរាជការស៊ីវិលដែលស្នើសុំឬលុបប្រាក់វិភាជន៍គ្រួសារនិងភ្ជាប់ឯកសារពាក់ព័ន្ធពិតប្រាកនោះ ត្រូវរក្សាទុកមួយច្បាប់នៅអង្គភាពរបស់ខ្លួននិងបញ្ជីរាយនាមកូន និង/ឬ សហព័ន្ធរបស់មន្ត្រីរាជការស៊ីវិលដែលស្នើសុំឬលុបប្រាក់វិភាជន៍គ្រួសារមួយច្បាប់ទៀត សម្រាប់ភ្ជាប់ជាមួយនឹងរបាយការណ៍ស្តីពីការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលនិងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការស៊ីវិល ដើម្បីធ្វើបច្ចុប្បន្នភាពក្នុងតារាងទូទាត់បៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យា
- មន្ត្រីទទួលបន្ទុកការងារបុគ្គលិក ត្រូវទទួលខុសត្រូវក្នុងការពិនិត្យនិងផ្ទៀងផ្ទាត់ជាប្រចាំចំពោះឯកសារពាក់ព័ន្ធនឹងបញ្ជីឈ្មោះកូន និង/ឬ សហព័ន្ធរបស់មន្ត្រីរាជការស៊ីវិលដែលស្នើសុំឬលុបប្រាក់វិភាជន៍គ្រួសារ ដើម្បីធានាថាការប្រើប្រាស់ប្រាក់វិភាជន៍គ្រួសារ ត្រឹមត្រូវតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

សូមជូនភ្ជាប់មកជាមួយនូវគំរូបញ្ជីឈ្មោះកូន និង/ឬ សហព័ន្ធរបស់មន្ត្រីរាជការស៊ីវិលដែលស្នើសុំឬលុបប្រាក់វិភាជន៍គ្រួសារ។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើសូម សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និង ឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត មេត្តាចូលរួមសហការអនុវត្តតាមការគួរ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ពេជ្រ ប៊ុនធិន**

**<u>ចម្លងជូន៖</u>**

- ក្រសួងព្រះបរមរាជវាំង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- សាលារាជធានី ខេត្ត
  "ដើម្បីជូនជ្រាប"
- មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង/សាលារាជធានី ខេត្ត/មន្ទីរ............
លេខ:........................................................

## បញ្ជីរាយនាមកូន និង/ឬ សហព័ន្ធរបស់មន្ត្រីរាជការស៊ីវិល
## ដែលត្រូវស្នើសុំឬលុបប្រាក់វិភាជន៍គ្រួសារ
## សម្រាប់ខែ ឆ្នាំ២០.......

| អត្តសញ្ញាណមន្ត្រីរាជការស៊ីវិល | | | | អត្តសញ្ញាណកូននិង/ឬសហព័ន្ធ | | | លេខនិងកាលបរិច្ឆេទនៃឯកសារភ្ជាប់ |
|---|---|---|---|---|---|---|---|
| ល.រ | អត្តលេខ | គោត្តនាមនិងនាម | ភេទ | គោត្តនាមនិងនាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | |
| កូនដែលត្រូវស្នើសុំប្រាក់វិភាជន៍គ្រួសារ | | | | | | | |
| ១ | | | | | | | |
| ២ | | | | | | | |
| សហព័ន្ធដែលត្រូវស្នើសុំប្រាក់វិភាជន៍គ្រួសារ | | | | | | | |
| ១ | | | | | | | |
| ២ | | | | | | | |
| កូនដែលត្រូវស្នើសុំលុបប្រាក់វិភាជន៍គ្រួសារ | | | | | | | |
| ១ | | | | | | | |
| ២ | | | | | | | |
| សហព័ន្ធដែលត្រូវស្នើសុំលុបប្រាក់វិភាជន៍គ្រួសារ | | | | | | | |
| ១ | | | | | | | |
| ២ | | | | | | | |

សរុបៈ - ស្នើសុំប្រាក់វិភាជន៍គ្រួសារសម្រាប់កូនចំនួន..........នាក់(........................នាក់) និង សហព័ន្ធចំនួន..........នាក់(...........................នាក់)
- ស្នើសុំលុបប្រាក់វិភាជន៍គ្រួសារសម្រាប់កូនចំនួន..........នាក់(........................នាក់) និង សហព័ន្ធចំនួន..........នាក់(...........................នាក់)

ធ្វើនៅ............. ថ្ងៃទី ខែ ឆ្នាំ២០...
ប្រធាននាយកដ្ឋានបុគ្គលិក/នាយកទីចាត់ការធនធានមនុស្ស/ប្រធានអង្គភាពគ្រប់គ្រងបុគ្គលិក

បានឃើញនិងឯកភាព
ធ្វើនៅ............. ថ្ងៃទី ខែ ឆ្នាំ២០...
រដ្ឋមន្ត្រី/អភិបាលរាជធានី ខេត្ត/ប្រធានមន្ទីរ-អង្គភាពជំនាញ